**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

~~~~~~~

**លេខ:** ០៦ ស.ណ.ខ.៣៨

## សារលិខិតជូនពរ

### សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧

**សម្ដេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏មង្គលសួស្ដីប្រសើរថ្លៃថ្លា ប្រកបដោយសេចក្ដីអភិរម្យសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំ ថ្មីប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥ និងទី១៦ ខែមេសាខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្ដីការគណៈរដ្ឋមន្ត្រី ខ្ញុំ និងភរិយា សូមអភិវន្ទសម្ដែងនូវសេចក្ដីអណរសាទរឥតឧបមា ប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត និងចូលរួមជូននូវសព្ទសាធុការពរជ័យ បវរសួស្ដី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាង ចំពោះសម្ដេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា និងលោកជំទាវ ក្នុងមនោសញ្ចេតនាប្រកបដោយសេចក្ដីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត សូមសម្ដេច និងលោកជំទាវប្រកបដោយកាយពលមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាឈ្លាសវៃ សុខភាពល្អបរិបូណ៌ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំរដ្ឋសភាជាស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រម្ពុជា សម្រេចបាននូវលទ្ធផលផ្លែផ្កាថ្មីៗធំធេងថែមទៀត រួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្សសេចក្ដីថ្លៃថ្នូរជាមូលដ្ឋាន ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យ ដែលនឹងជួយជម្រុញដល់ការអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ នៃរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា ក្នុងការអភិវឌ្ឍសង្គមជាតិប្រកបដោយជោគជ័យ និងនាំមកនូវភាពរីកចម្រើនជឿនលឿនលើគ្រប់វិស័យយ៉ាងឆាប់រហ័ស។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លាជ័យមង្គលាភិរម្យនេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្ដសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លាព្រះអង្គចេក ព្រះអង្គចម ពិសេសទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ព្រះនាម **កិមិរាទេវី** សូមព្រះអង្គតាមជួយអភិបាលប្រោះព្រំសព្ទសាធុការពរជ័យគ្រប់ប្រការ ចំពោះសម្ដេចប្រធាន និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ និងសូមសម្ដេចអគ្គមហាពញាចក្រី និងលោកជំទាវ សមប្រកបដោយពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្ដេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា និងលោកជំទាវ មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងភក្ដីភាពដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ និងភរិយា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃទីស្ដីការគណៈរដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**ប៊ិន ឈិន**
~~~~~~~